# sløQI

Tree leaves

SOR Bopha

កណ្តាលយប់ស្ងាត់ រថយន្តឡង់គ្រីស័រមួយគ្រឿងកំពុងបោះពួយតាមដងវិថីមួយនៃទីក្រុងក្នុងល្បឿនដ៏លឿនគួរឱ្យព្រឺខ្លាច មកដល់មុខភូមិគ្រឹះធំមួយ រថយន្តក៏ឈប់រួចបន្លឺស៊ីផ្លេទីន១ ញាប់រន្ថើនលាន់ទ្រហឹង ដូចជាមិនខ្លាចក្រែងរំខានដំណេកអ្នកជិតខាងដែលកំពុងលង់លក់នោះឡើយ។ មួយស្របក់តូច ទ្វាររបងបានបើកឡើងដោយដៃអ្នកបំរើម្នាក់រួចហើយបិទទៅវិញនៅពេលរថយន្តចូលផុត។ អ្នកបំរើម្នាក់ទៀតស្ទុះមកបើកទ្វារយាន បុរសម្នាក់រាងទាបល្អិតចេញមករួចដើរចូលក្នុងភូមិគ្រឹះទាំងដំណើរទ្រេតទ្រោតដោយអាការៈស្រវឹង បន្ទាប់មកពីដើរផឹកស៊ីសប្បាយជាមួយស្រីញីអស់ចិត្ត។

ម្ចាស់ភូមិគ្រឹះជាមន្ត្រីម្នាក់ លោកឈ្មោះសំណល់ ភរិយាឈ្មោះណារី គ្រួសារនេះមានបុត្រទោលម្នាក់ឈ្មោះសុមេធ អាយុ២៤ឆ្នាំ ជានិស្សិតមហាវិទ្យាល័យនីតិសាស្ត្រឆ្នាំទី៣។ គេមានរាងខ្ពស់ស្រឡះដែលផ្ទុយពីឪពុកគេ ទាំងមុខមាត់ទាំងចិត្តគំនិត។ លោកសំណល់ជាមនុស្សប៉ិនប្រសប់ខាងអែបអបយកគាប់គួរចៅហ្វាយនាយ បើនិយាយពីកំរិតវប្បធម៌ លោករៀនមិនបានចប់អនុវិទ្យាល័យផង មានចំណេះដឹងតិចនិងបទពិសោធន៍ការងារក៏ស្មើរ ប៉ុន្តែបុណ្យសក្តិលោកចេះតែឡើងឥតឈប់ឈរ ដោយសារទាក់ទងត្រូវចំខ្សែចំបក្សពួកនិងពូកែផ្គាប់ផ្គុនថ្នាក់លើខ្លួន ទោះបីមានអ្នកមិនពេញចិត្តនូវទង្វើខ្លួនក៏លោកមិនខ្វល់ សំខាន់គឺធ្វើយ៉ាងណាឱ្យតែចៅហ្វាយនាយពេញចិត្ត។ ព្រោះតែអាងបុណ្យសក្តិអាងខ្សែនិងបក្សពួក ធ្វើឱ្យលោកមានអំនួតក្អេងក្អាងរហូតដល់ហ៊ានធ្វើអ្វីៗដោយមិនខ្លាចច្បាប់ ដូចជាប្រព្រឹត្តអំពើពុករលួយស៊ីសំណូក ឃុបឃិតជាមួយឈ្មួញទុច្ចរិត យកមកធ្វើមានធ្វើបានផ្ទាល់ខ្លួនផងនិងយកទៅជូនចៅហ្វាយនាយផងដើម្បីរក្សាការពារតំណែងឱ្យបានគង់វង្ស។ សព្វថ្ងៃ

s.báö

លោកកើតនៅថ្ងៃទី២៨ មិនា ឆ្នាំ១៩៥៨ នៅសង្កាត់លេខបី ក្រុងភ្នំពេញ។ លោកបានទៅបន្តការសិក្សានៅសហភាពសូវៀត ផ្នែកសេដ្ឋកិច្ច ពីឆ្នាំ១៩៨២ ដល់ឆ្នាំ១៩៨៧ ហើយបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ និងឥណទាន។ លោកធ្លាប់ជាអតីតមន្ត្រីធនាគារជាតិ រួចបានចាប់ផ្តើមសរសេរសេណារីយ៉ូ សំរាប់ខ្សែភាពយន្តនៅចុងឆ្នាំ១៩៨៨។ ស្នាដៃរបស់លោកមានប្រលោមលោកខ្នាតវែងចំនួនពីររឿង ដែលក្នុងនោះរឿងមួយជាប់ពានរង្វាន់ព្រះសីហនុរាជ ឆ្នាំ២០០១។ ក្រៅពីការសរសេរប្រលោមលោក លោកបានបកប្រែរឿងខ្លីៗពីភាសាអង់គ្លេសមកជាភាសាខ្មែរ ព្រមទាំងបានសរសេរអត្ថបទស្រាវជ្រាវមួយចំនួនដែលបានចុះផ្សាយនៅកាសែតរស្មីកម្ពុជា។

លោកមិនត្រឹមតែមានភូមិគ្រឹះតូចធំ៥កន្លែងដាក់ជួល រថយន្តទំនើបៗ៤គ្រឿង ដីធ្លីរាប់សិបហិកតាប៉ុណ្ណោះទេ មានទាំងប្រាក់ផ្ញើនៅធនាគារឯក្រៅប្រទេសទៀតផង។ ដោយសារប្រាក់បានដោយងាយពីអំពើមិនស្របច្បាប់ លោកសំណល់បានយកទៅសប្បាយហ៊ឺហា ផឹក ស៊ីស្រីញីអូនបងនៅតាមភោជនីយដ្ឋាន បារ រង្គសាល ការ៉ាអូខេ រហូតរំលងអាធ្រាតទើបចូលផ្ទះ។ ពេលចុះបំពេញការងារតាមខេត្តម្តងៗ លោកសប្បាយណាស់ដែលមានកូនចៅចេះអែបអបដឹងចិត្តចៅហ្វាយ នាំទៅស៊ីផឹក រួចបន្តការសប្បាយតាមហាងការ៉ាអូខេ និងចុងក្រោយគឺតែងរកស្រីក្មេងៗស្អាតៗនៅស៊ីន(បរិសុទ្ធ)មកឱ្យកំដរអារម្មណ៍ជប់លៀងអាស្រមូមទៀតផង។

សុមេធជាយុវជនឧស្សាហ៍ព្យាយាមនឹងការសិក្សា មានសច្ចធម៌ ចេះជួយអ្នកដទៃ ស្អប់ខ្ពើមអំពើអយុត្តិធម៌ បានទទួលការស្រលាញ់ថ្នាក់ថ្នមពីឪពុកម្តាយ និងមានប្រាក់ចាយមិនខ្វះ តែនាយជាក្មេងមានការអប់រំល្អចេះគិតពិចារណា រាល់ការចាយវាយសុទ្ធតែមានហេតុផលត្រឹមត្រូវ មិនដូចកូនលោកធំខ្លះនិងកូនអ្នកមានមួយចំនួនអាងទ្រព្យសម្បត្តិឪពុកម្តាយ ចាយវាយខ្ជះខ្ជាយឥតបើគិត គេចពីសាលាទៅដើរលេងសប្បាយហ៊ឺហារហូតមានបងតូចបងធំ នាំអំពល់ទុក្ខដល់គ្រួសារដល់សង្គមទៀតផង។ ថ្ងៃមួយសុមេធត្រលប់ពីរៀនមកផ្ទះ ពេលដើរកាត់បន្ទប់ទទួលភ្ញៀវស្រាប់តែឃើញភ្ញៀវម្នាក់កំពុងប្រគល់របស់អ្វីមួយមើលទៅទំនងជាដុំក្រដាសប្រាក់ទៅឱ្យឪពុកខ្លួន។ នាយចង់តែស្ទុះទៅជិតមើលឱ្យច្បាស់និងចង់ដឹង តើអ្នកទាំងពីរកំពុងធ្វើអ្វី? ប៉ុន្តែគិតដល់សុជីវធម៌នាយក៏ដើរហួសទៅ។ ក្រោយពីភ្ញៀវចេញទៅ លោកសំណល់បានហៅកូនប្រុសមកជួបហើយដកក្រដាសប្រាក់ដុល្លារប្រភេទ១០០ប្រមាណជា៥សន្លឹកពីដុំដែលទើបបានពីភ្ញៀវហុចទៅឱ្យកូន ÷

-ហ៎នែ! ប៉ាឱ្យកូនទុកចាយ បើមិនគ្រាន់ចាំយកពីម៉ាក់កូនទៀត។

សុមេធបើកភ្នែកធំៗសម្លឹងមើលក្រដាសប្រាក់ដុល្លារ រួចមើលមុខឪពុក ÷

-លោកប៉ា នេះជាលុយអី?

-កុំសួរច្រើន ប៉ាឱ្យហើយយកទៅ។ លុយនេះគេជូនប៉ាជាសគុណទេ យកទៅកូន។

សំដីនេះគ្រប់គ្រាន់ណាស់សំរាប់សុមេធ នាយឆ្លើយទាំងមុខមាំ ÷

-ខ្ញុំមិនត្រូវការលុយនេះទេ លោកប៉ាទុកចាយខ្លួនឯងចុះ។

បន្លីរួចនាយដើរចេញទៅ ក្រោមក្រសែភ្នែកតាមមើលរបស់ឪពុកទាំងឆ្ងល់ក្នុងចិត្តនឹងឫកពាចម្លែករបស់កូន។ មួយថ្ងៃក្រោយមកនាពេលបាយល្ងាច លោកស្រីបានប្រាប់អ្នកបំរើម្នាក់ឱ្យទៅតាមកូនប្រុសមកហូបបាយ។ ស្រីបំរើចេញទៅមួយភ្លែតក៏រត់ត្រលប់មកវិញទាំងត្រហេបត្រហប ÷

-លោកស្រី លោកស្រី អ្នកប្រុស...

លោកស្រីណារីកំពុងជួសម្លូបដាក់ចាន ភ្ញាក់នឹងសំលេងអ្នកបំរើ ÷

-មានរឿងអីក៏សស្លើតសស្លក់ម្លេះ កូនអញវាយ៉ាងម៉េច?

-អត់ឃើញអ្នកប្រុសទេ ឃើញតែសំបុត្រ។

ស្រីបំរើបន្ទីព្រមទាំងហុចក្រដាសមួយសន្លឹកទៅឱ្យលោកស្រីទទួលយកមកអានបានបន្តិច ស្រាប់តែយំហ្ញឹ លោកសំណល់ក៏យកពីដៃភរិយាមកអានម្តង ÷

*លោកប៉ាជាទីគោរព!*

*អ្នកម៉ាក់ជាទីស្រលាញ់!*

*នៅពេលដែលលោកទាំងពីរកំពុងអានសំបុត្រនេះ ក៏ជាពេលដែលរូបកូនបានឃ្លាតឆ្ងាយពីអ្នកមានគុណដែរ។ លោកប៉ាអ្នកម៉ាក់ប្រាកដជាងឿងឆ្ងល់និងចង់សួរកូនថា តើកូនមានរឿងអ្វីបានជាចេញពីផ្ទះដោយមិនមានប្រាប់ប៉ាម៉ាក់យ៉ាងនេះ? តើពេលនេះកូនទៅនៅកន្លែងណា? បានសុខឬទុក្ខ? មានរឿងជាច្រើនដែលកូនចង់និយាយ។ លោកប៉ាជាអ្នកមានគុណរបស់កូន កូនមិនអាចយកការពិតមួយចំនួនមកប្រឈមមុខជាមួយលោកប៉ាបានទេ ហេតុនេះទើបកូនសរសេរជាសំបុត្រប្រាប់ពីមូលហេតុ ÷*

*កាលពីមុនមានគេនិយាយអាក្រក់ពីលោកប៉ា កូនមិនត្រឹមតែមិនជឿទេថែមទាំងការពារលោកប៉ាទៀតផង តែពេលនេះកូនបានឃើញផ្ទាល់ភ្នែកនូវអ្វីដែលលោកប៉ាបានប្រព្រឹត្ត ធ្វើឱ្យកូនអស់សង្ឃឹមណាស់។ លោកប៉ាជាមន្ត្រីរាជការមួយរូបដែលរាស្ត្របានប្រគល់សិទ្ធិ ខំផ្ញើការទុកចិត្តនិងក្តីសង្ឃឹម តែលោកប៉ាបែរជាយកអំណាចទៅបំរើពួកឈ្មួញទុច្ចរិត បំពេញមហិច្ឆតាខ្លួន បំផ្លាញជាតិ សំលាប់រាស្ត្រទៅវិញ លោកប៉ាធ្វើនេះមិនខ្លាចមានបាបកម្មទេវី? ពីមុនកូននៅតូច កូនតែងសរសើរខ្លួនឯងដែលបានទទួលការស្រលាញ់ថ្នាក់ថ្នម ភាពកក់ក្តៅ ក្តីសង្ឃឹមនិងអ្វីៗសព្វយ៉ាងពីលោកទាំងពីរ តែពីពេលនេះទៅកូនលែងមានវាសនាទៀតហើយ។ ពេលនេះកូនធំហើយ ដឹងល្អអាក្រក់ស្គាល់បុណ្យបាប កូនត្រូវការអភិវឌ្ឍខ្លួន ចង់ធ្វើខ្លួនឱ្យទៅជាមនុស្សថ្មីឱ្យមានប្រយោជន៍ដល់ខ្លួននិងសង្គម ចង់រស់ដោយពឹងលើចំណេះនិងសមត្ថភាពខ្លួន មិនត្រូវការរស់ដោយសារលុយស្មោកគ្រោករបស់លោកប៉ាទៀតទេ។*

*បើអាណិតស្រលាញ់កូនសូមកុំតាមរកកូនអី ទុកឱ្យកូនរស់ដោយសុខស្រួលផងចុះ នៅពេលបានទទួលជោគជ័យក្នុងជីវិតហើយ កូនគង់តែត្រលប់មករកអ្នកមានគុណវិញជាមិនខានទេ។*

*ពីកូន*

*សុមេធ*

អានចប់ លោកសំណល់ក្តុកក្តួលអារម្មណ៍ បន្លឺក្នុងចិត្ត «សុមេធកូននៅក្មេងណាស់ មិនទាន់ស្គាល់ការរាក់ជ្រៅក្នុងសង្គមទេ។ ថ្ងៃក្រោយពេលកូនចូលប្រឡូកក្នុងសង្គម កូនក៏ដូចជាប៉ាអញ្ចឹងដែរ»។ លោកស្រីណារីបន្លឺទាំងទឹកភ្នែក ÷

-ប៉ាវានៅឈរធ្មឹងដល់ណាទៀត មិនគិតទៅតាមកូនមកវិញទេឬយ៉ាងម៉េច? ឱ! កូនមាសម្តាយ ធ្លាប់តែរស់ស្រួលមានអីស្រាប់ៗ ពេលនេះមិនដឹងជាជួបការលំបាកយ៉ាងណាទេ ម៉ាក់អាណិតកូនណាស់ ហ៊ឺ...ហ៊ឺ...

-ម៉ាក់វាកុំកើតទុក្ខពេក បងថាវាទៅមិនយូរទេមុខជាត្រលប់មកវិញមិនខាន។

-ចុះបើកូនទៅរហូត បងគិតយ៉ាងម៉េចវិញ? បើកូនយ៉ាងម៉េចយ៉ាងម៉ា អូនមិនអត់ឱនឱ្យបងទេ!

-បានៗ ចាំបងឱ្យគេទៅតាមហៅវាមកវិញ។

បន្ទាប់មក លោកសំណល់បានចាត់ឱ្យអ្នកនៅក្រោមឱវាទចេញទៅតាមរកភ្លាមដែរ ចំណែកលោកស្រីក៏បានទូរស័ព្ទទៅគ្រប់ទីកន្លែងដែលស្គាល់សួរដំណឹងពីកូនទាំងក្តីបារម្ភ។

និយាយពីសុមេធ ពេលចេញទៅនេះមិនមានយកអ្វីទៅជាមួយទេ មានតែសំលៀកបំពាក់ជាប់ខ្លួននិងប្រាក់បន្តិចបន្តួចដែលសល់ក្នុងហោប៉ៅតែប៉ុណ្ណោះ។ នាយចេះតែដើរៗទៅទាំងគ្មានទីដៅក្នុងចិត្តស្មុគស្មាញរកគិតអ្វី ក៏មិនចេញ។ កំពុងខ្វល់ចិត្ត ស្រាប់តែភ្ញាក់នឹងសំលេងមួយ ÷

-ពូៗ ឱ្យសុំមួយរយមក៏ ទិញបាយហូប។

នាយកំលោះយើងងាកទៅ ឃើញស្ត្រីសុំទានម្នាក់មុខស្លេកស្លាំង រាងកាយស្គាំងស្គម ដៃម្ខាងដឹកដៃក្មេងប្រុសសំគមម្នាក់និងដៃម្ខាងទៀតពកូនក្មេងអាយុប្រហែលជាងមួយខួប ភ្នែកបិទមាត់ហាម្លបៗដូចកំពុងស្រេកឃ្លានខ្លាំងណាស់។ នាយយើងមិនទាន់ឆ្លើយថាដូចម្តេចផង ស្ត្រីទុរគតពោលបន្ថែមទាំងទឹកភ្នែក ÷

-ខ្ញុំនិងកូនអត់បាយពីរថ្ងៃហើយ សូមពូមេត្តាដាក់ទានឱ្យបានទិញបាយហូបបានរស់នឹងគេផង។

ឮសំដីដ៏គួរឱ្យខ្លោចផ្សានេះ សុមេធលូកយកប្រាក់ដែលមានទាំងអស់ហុចទៅឱ្យ ស្ត្រីទុរគតទទួលយកដោយក្តីអំណរនិងជូនពរ ÷

-សូមពូបានជួបតែសេចក្តីសុខ ប្រាថ្នាអ្វីបានសំរេចដូចបំណង ទៅណាមកណាទេវតាតាមថែរក្សាជានិច្ច។ ពោលចប់ នាងដឹកដៃកូនដើរចេញទៅ ទុកឱ្យនាយយើងឈរមើលទាំងបន្លឺក្នុងចិត្ត «ឱ! ជីវិតអញគិតថាខ្លួនឯងកំសត់ មានគេកំសត់និងវេទនាជាងអញទៅទៀត»។ រួចហើយនាយបន្តដំណើរទៅទៀត ដើររហូតដល់ថ្ងៃលិចក៏មិនដឹងត្រូវទៅទីណាកន្លែងណា។ ពោះចាប់ផ្តើមកូរ នាយទទួលអារម្មណ៍ថាឃ្លានក៏ដើររកកន្លែងលក់បាយ។ រៀបនឹងចូលទៅហើយ តែពេលស្ទាប

ហោប៉ៅគ្មានប្រាក់ក៏ឈរធ្មឹង សម្លឹងបាយម្ហូបអ្នកលក់ទាំងលេបទឹកមាត់ក្អឹកៗ ដោយការឃ្លាន។ នាយដើរចេញទាំងគិតថា «ឱ! អញអើយ ធ្លាប់តែដេកស្រួល ស៊ីស្រាប់មិនគួរធ្លាក់ខ្លួនយ៉ាងនេះសោះ។ នៅលើលោកយើងនេះគ្មានអ្វីឱ្យពិតប្រាកដនិងទៀងទាត់ឡើយ ជីវិតកើតចាស់ឈឺស្លាប់តែងវិលចុះវិលឡើងដូចកង់រទេះ នេះហើយជាវាលវដ្តសង្សារដែលព្រះពុទ្ធបានសំដែង។ អ្វីៗទាំងអស់មិនមែនជាកម្មសិទ្ធិរបស់អ្នកណាម្នាក់ទេ គឺសុទ្ធតែជារបស់បណ្ដោះអាសន្នទាំងអស់ សូម្បីខ្លួនប្រាណ និងដង្ហើមដែលកំពុងតែដកក៏ដោយ។ វាគ្រាន់តែជាគ្រឿងបំភាន់ភ្នែកបញ្ឆោតចិត្តពង្វក់អារម្មណ៍ប៉ុណ្ណោះ មានតែរបស់ហូបចូលទៅក្នុងពោះទេទើបជារបស់យើងពិតប្រាកដ ព្រោះគ្មានអ្នកណាម្នាក់អាចមកឆក់ដណ្ដើមយកពីយើងបានឡើយ»។

ក្នុងពេលស្មុគចិត្តទាល់គំនិតនេះ នាយក៏បានមកដល់ផ្ទះម្ដាយមីងដែលត្រូវជាបងស្រីម្ដាយខ្លួន។ មីងភ្លូងឃើញក្មួយដើរកាត់មុខផ្ទះក៏ស្រែកហៅឱ្យចូលលេងនឹងឃាត់ឱ្យនៅហូបបាយ នាយយើងមិនបានបដិសេធទេ ព្រោះកំពុងឃ្លានស្រាប់ផង។ ក្រោយពេលហូបរួច មីងនិងក្មួយបានជជែកគ្នាលេងពីនេះពីនោះ។ សុមេធបាននិយាយរឿងខ្លួនប្រាប់ដល់គាត់ដោយគ្មានលាក់លៀម ស្ដាប់រួចអ្នកមីងមានចិត្តអាណិតក្មួយជាខ្លាំងក៏ឃាត់នាយឱ្យស្នាក់នៅផ្ទះគាត់ជាបណ្ដោះអាសន្នមួយរយៈសិន នាយក៏យល់ព្រមព្រោះគ្មានជំរើស។ គ្រួសារនេះមានសមាជិកប្រាំនាក់ អ្នកមីងជាស្រីមេម៉ាយសព្វថ្ងៃរស់នៅជាមួយកូនស្រីជាគ្រូបង្រៀន និងកូនប្រសាជាមន្ត្រីរាជការ ឆ្លៀតពេលទំនេររត់ម៉ូតូឌុបរកកម្រៃបន្ថែម និងចៅទាំងពីរកំពុងរៀន។

ក្នុងយប់នោះសុមេធគេងមិនលក់សោះ គិតនេះគិតនោះមិនចេះចប់។ នាយគិតថាមិនគួរមករំខានដល់ម្ដាយមីងសោះព្រោះជីវភាពគាត់ក៏មិនជាធូរធាប៉ុន្មានទេ ខ្លួនត្រូវតែរកការធ្វើយកប្រាក់មកជួយសំរួលដល់ការខ្វះខាតរបស់គាត់។ នាយគិតក្នុងចិត្ត ÷ «គ្រួសារក្រមែនពិតតែមើលទៅដូចជាមានសេចក្ដីសុខណាស់។ មិនមែនបានន័យថាអ្នកក្រមិនចេះកើតទុក្ខនោះទេ មនុស្សគ្រប់រូបមិនថាអ្នកក្រអ្នកមានលោកតូចលោកធំសុទ្ធតែមានទុក្ខគ្រប់គ្នា គ្រាន់តែទុក្ខនោះមានលក្ខណៈខុសៗគ្នាទៅតាមថ្នាក់របស់វា តែមានរបស់មួយដូចគ្នាហើយដែលគ្មានអ្នកណាម្នាក់ចៀសរួចឬគេចផុតបានឡើយ គឺសេចក្ដី «ស្លាប់» មនុស្សម្នាក់ៗដឹងថាពេលកើតមកខ្លួនទទេ ហើយពេលស្លាប់ទៅវិញក៏ដៃទទេដែរ ហេតុដូចម្ដេចក៏មនុស្សនៅតែមានមហិច្ឆតាគ្មានទីបញ្ចប់?»។

ព្រឹកស្អែកឡើង បន្ទាប់ពីរៀបចំខ្លួនរួចបំរុងចេញទៅសាលារៀន នាយទុចដំណើរដោយឃើញម្ដាយឈរនៅមុខផ្ទះទាំងទឹកភ្នែករលីងរលោង។ លោកស្រីបន្លឺទៅកាន់កូនដោយអង្វរករ ÷

-កូនមេធ កុំប្រកាន់ខឹងនឹងប៉ាកូនអី ប៉ាធ្វើនេះក៏ព្រោះតែកូនដែរ ទៅផ្ទះវិញជាមួយម៉ាក់ទៅណា។

សុមេធនៅស្ងៀមក្នុងចិត្តច្របូកច្របល់ លោកស្រីពោលបន្ត÷

-ប៉ានិងម៉ាក់មិនអាចរស់ដោយគ្មានកូនបានទេ ហើយក៏មិនចង់ឃើញកូនលំបាកវេទនាដែរ ទៅវិញជាមួយម៉ាក់ទៅណា!

-សុំទោសម៉ាក់ កូនបានសំរេចចិត្តហើយថាមិនទៅវិញទេ។

-អញ្ចឹង កូនមិនអាណិតម៉ាក់ទេវី?

-ម៉ាក់នៅតែជាម៉ាក់របស់កូនដដែល ប៉ាក៏នៅតែជាប៉ាដដែល តែពេលនេះចិត្តនិងគំនិតកូនមិននៅដដែលទៀតទេ។ កូនចង់រស់ដោយខ្លួនឯងនិងចង់ដឹងដែរថា បើអត់លុយស្មោកគ្រោករបស់លោកប៉ា តើកូនអាចស្លាប់ទេ? បើស្លាប់មែនក៏ស្លាប់ទៅចុះ។

ឮសំដីកូន លោកស្រីយំហ្ម៖

-ទេ! កូនកុំនិយាយអញ្ចឹង ម៉ាក់ខ្លាចណាស់មិនចង់ឮពាក្យនេះទេ។

-ម៉ាក់កុំបារម្ភ មនុស្សយើងមិនអាចស្លាប់ដោយងាយៗនោះទេ កូននឹងអត់ធ្មត់តស៊ូនឹងជីវិតទោះជាលំបាកយ៉ាងណាក៏កូនអាចទ្រាំបានដែរ។

-ពុទ្ធោ! កូនម៉ាក់...

-បើម៉ាក់ស្រលាញ់កូន ចង់ឱ្យកូនល្អ សូមកុំមករំខានកូនអី ទុកឱ្យកូនរស់ដោយសុខស្រួលនិងស្ងាត់ស្ងៀមផង។

លោកស្រីណារីអស់ពាក្យនិយាយ បានត្រឹមតែបង្ហូរទឹកភ្នែកគួរឱ្យអាណិត។ មីងភួងឈរស្តាប់ការឆ្លើយឆ្លងនេះ ឃើញថាមិនអាចដោះស្រាយបញ្ហាបានក៏ចូលធ្វើអន្តរាគមន៍។ អ្នកមីងបានប្រាប់ប្អូនស្រីថា មិនត្រូវបង្ខំចិត្តកូននៅពេលនេះទេព្រោះកូនកំពុងមានអារម្មណ៍មិនល្អ ទុកពេលឱ្យគាត់និយាយបញ្ចុះបញ្ចូលវិញ លោកស្រីស្តាប់ហើយក៏យល់ស្រប។ មុននឹងត្រលប់ទៅវិញ លោកស្រីបានផ្តែផ្តាំនិងប្រគល់ប្រាក់មួយចំនួនឱ្យបងស្រីទុក សំរាប់ការចាយវាយរបស់កូនដោយមិនឱ្យនាយយើងដឹងឡើយ។

ក្នុងការស្នាក់អាស្រ័យនេះ សុមេធបានទទួលការផ្គត់ផ្គង់ពីម្តាយមីងមិនមានខ្វះ ធ្វើឱ្យនាយរំភើបចិត្តគិតថា គាត់ជាអ្នកមានគុណដែលនាយមិនអាចបំភ្លេចបានឡើយ។ មីងភួងតែងដាស់តឿនឱ្យក្មួយត្រលប់ទៅផ្ទះវិញ ប៉ុន្តែនាយយើងបានបដិសេធ និងសូមឱ្យម្តាយមីងឈប់និយាយពីរឿងនេះបើអាណិតស្រលាញ់ខ្លួន។ ពេលក្រោយមកទៀតលោកស្រីណារីចេះតែមកតាមអង្វរកូន និងពេលដឹងថាខ្លួនរស់ដោយសារប្រាក់ដែលម្តាយលួចផ្តល់ឱ្យ នាយយើងពិបាកក្នុងចិត្តនិងចង់គេចពីបញ្ហាក៏លួចចេញពីផ្ទះម្តាយមីងទៅសុំវត្តលោកស្នាក់នៅ ធ្វើឱ្យលោកស្រីរឹតតែសោកសង្រេងតាមរកកូនសឹងឆ្កួត

ហើយចង់ប្រកាសរកកូនតាមសារព័ត៌មាននិងទូរទស្សន៍ តែស្វាមីមិនយល់ស្របព្រោះគិតថាជាការអាម៉ាស់។

សុមេធមានគូដណ្តឹងម្នាក់ដែលឪពុកម្តាយទាំងសងខាងបានភ្ជាប់ពាក្យគ្នារួចហើយ រង់ចាំតែថ្ងៃរៀបការ នៅពេលណានាយបានបញ្ចប់ការសិក្សាតែប៉ុណ្ណោះ។ នាងឈ្មោះភក្តី អាយុ១៩ឆ្នាំ រៀននៅវិទ្យាល័យថ្នាក់ទីបញ្ចប់។ ឪពុកនាងក៏ជាមន្ត្រីរាជការមានបួកពាស្លូតបូត ឯម្តាយជាមេផ្ទះ។ ពេលដឹងថាគូដណ្តឹងបាត់ខ្លួនពីផ្ទះ នាងក៏បានជួយតាមរកជាមួយម្តាយក្មេកដែរ ដោយខ្វល់ខ្វាយដល់សុខទុក្ខប្រុសស្នេហ៍។ នៅវត្តដែលនាយសុំស្នាក់ ក៏មានយុវជនជាច្រើនមកស្នាក់រៀនបន្តនៅទីក្រុងក្រោយពីបានបញ្ចប់ការសិក្សានៅខេត្តរបស់ខ្លួន។ សុមេធនិងពួកគេបានស្រលាញ់រាប់គ្នាជាមិត្តយ៉ាងស្និទ្ធស្នាល។ ដោយការអាណិតស្រលាញ់ ព្រះសង្ឃមេកុដិបានផ្តល់បាយទឹក និងប្រាក់កាសខ្លះៗជួយដល់សុមេធផងដែរ។ នាយគិតថាវត្តអារាមមានសារប្រយោជន៍ច្រើនណាស់ មិនមែនគ្រាន់តែជាទីសក្ការៈគោរពបូជានិងអប់រំចិត្តតាមផ្លូវធម៌ព្រះប៉ុណ្ណោះទេ តែក៏ជាទីស្ងប់ស្ងាត់សំរាប់តាំងសមាធិរំងាប់អារម្មណ៍រំដោះទុក្ខ ជាទីស្នាក់អាស្រ័យដល់ជនគ្រប់រូបដែលមានវិបត្តិផ្សេងៗឬដាច់សង្វេង។ សុមេធមិនបានផ្តេកផ្តួលខ្លួនតាមយថាកម្មទេ នាយយល់ថាជីវិតគឺជាការតស៊ូ មិនត្រូវធ្វើខ្លួនជាបញ្ញើក្អែកចាំតែដេកស៊ីរស់ដោយសារបាយវត្តស្រាប់ៗនោះទេ ត្រូវចេះជួយខ្លួនឯងជាមុនសិនមុននឹងត្រូវការឱ្យអ្នកដទៃជួយយើង ដូចព្រះសម្មាសម្ពុទ្ធបានសំដែងថា «អត្តាហិ អត្តនោនាថោ» មានន័យថា «ខ្លួនត្រូវទីពឹងខ្លួន»។ ពេលទំនេរនាយទៅយកសារព័ត៌មាន ទស្សនាវដ្តីពីតូបអ្នកលក់ដើរលក់តាមកន្លែងនានា ពេលយប់ធ្វើជាអ្នកបំរើភ្ញៀវក្នុងភោជនីយដ្ឋានដើម្បីរកប្រាក់មកបំពេញសេចក្តីត្រូវការរបស់ខ្លួន។ ព្រោះតែការខ្វះខាតនេះហើយដែលធ្វើឱ្យនាយទៅរៀនមិនបានទៀងពេលឡើយ ប៉ុន្តែក៏នៅតែព្យាយាមតស៊ូនឹងការសិក្សាជានិច្ច។

ថ្ងៃមួយកញ្ញាភក្តីបានដំណឹងពីមិត្តម្នាក់ ធីតាក៏មករកដល់ទីកន្លែងនាយស្នាក់នៅ។ ពេលឃើញសុមេធ ស្រីស្រស់ស្រែកហៅដោយអំណរ ÷

-បងមេធ បង...

ធីតាបន្លឺបានតែបីម៉ាត់ ទឹកភ្នែកក៏ហូរស្រក់មកដោយឯងៗព្រោះតែខ្លោចចិត្តអាណិតប្រុសស្នេហ៍ពេលឃើញនាយមានរាងកាយស្គមនិងខ្មៅជាងមុន។ សុមេធឈរសៀមមើលមុខគូដណ្តឹង ÷

-អូនសុខសប្បាយទេ?

-ចាស ចុះបងវិញ? ពេលដឹងដំណឹងពីម៉ាក់បង អូនខ្វល់ចិត្តនិងបារម្ភពីសុខទុក្ខបងណាស់។

-បងមិនអីទេ តែពេលនេះបងមិនមែនជាសុមេធដូចពីមុនទេ សូមអូនឈប់ទាក់ទងនឹងបងទៅ។

-ហេតុអីទៅ?
-បងជាមនុស្សគ្មានទីពឹងគ្មានទ្រព្យធន មិនអាចរកសុភមង្គលឱ្យអូនបានទេ អូនគួរតែរកអ្នកផ្សេងដែលល្អជាងបង។
-ទេ! ទោះបងក្លាយជាអីក៏ដោយ ក៏អូននៅតែស្រលាញ់បងជានិច្ច។ យើងជាគូដណ្តឹងនឹងគ្នា ទុក្ខរបស់បងក៏ជាទុក្ខរបស់អូនដែរ អូនស៊ូស្លាប់រស់ជាមួយបង។ បងធ្វើនេះពិតជាត្រឹមត្រូវសមជាកូនប្រុស អូនគាំទ្របងជានិច្ច។
ស្តាប់សំដីដ៏មានន័យនេះ សុមេធរំភើបចិត្តណាស់ ÷
-អរគុណអូនដែលនៅមានចិត្តស្មោះនិងផ្តល់កំលាំងចិត្តដល់បង ឱ្យបងមានចិត្តតស៊ូតទៅទៀត។
ស្រស់ស្រីដោះចិញ្ចៀនហុចឱ្យគូដណ្តឹង ព្រមជាមួយវាចា ÷
-អូនមិនបានជាប់លុយមកទេ បងយកចិញ្ចៀននេះទៅលក់សំរាប់ទុកចាយចុះ។
-ទេ នេះជាចិញ្ចៀនភ្ជាប់ពាក្យបើលក់វាដូចជាកាត់ផ្តាច់ស្នេហាយើងអញ្ចឹង អូនត្រូវរក្សាវាទុកឱ្យបានល្អ ឃើញអូនល្អនឹងបងយ៉ាងនេះ បងត្រេកអរណាស់ទៅហើយមិនចង់បានអីពីអូនទៀតទេ តែបងមានសំណូមពរមួយ គឺអូនមិនត្រូវប្រាប់អ្នកណាម្នាក់ថាបងនៅទីនេះទេជាពិសេសម៉ាក់បង ហើយអូនក៏កុំមករកបងញឹកញាប់ពេកដែរបើមិនមានការចាំបាច់។
-ចាស ដើម្បីបងអូនសូមសន្យា។
-អរគុណអូនណាស់ បានហើយអូនល្មមទៅវិញហើយកុំឱ្យប៉ាម៉ាក់អូនមើលផ្លូវ។
-ចាស អូនលាសិនហើយ សូមបងថែខ្លួនផង។
-អូនក៏អញ្ចឹងដែរ។
ភក្តីមើលមុខប្រុសស្នេហ៍បន្តិច ទើបដើរចេញទៅទាំងមិនអស់អាល័យ ចំណែកសុមេធតាមមើលគូដណ្តឹងទាំងរំជួលចិត្តរកថាមិនត្រូវ។

យប់មួយពេលលើកម្ហូបទៅឱ្យភ្ញៀវ សុមេធបានឃើញឪពុកខ្លួនកំពុងប្រកៀកប្រកើយជាមួយនារីវ័យក្មេងពីរនាក់ដែលអង្គុយអមសងខាង និងបុរសវ័យចំណាស់ពីរនាក់ទៀតក៏មានស្រីកំណាន់មួយម្នាក់អង្គុយកំដរផងដែរ។ នាយចង់គេចមុខ តែចួនជាលោកសំណាល់ងាកមកឃើញ ក៏ស្រែកហៅនិងពោលដោយទន់ភ្លន់ ÷
-សុមេធកូន! ទៅផ្ទះវិញទៅកូន ម៉ាក់កូនកំពុងព្រួយបារម្ភពីកូនណាស់ហើយប៉ាក៏ពិបាកចិត្តណាស់ដែរ មិនចង់ឃើញកូនលំបាកវេទនាបែបនេះទេ។
សុមេធស្តាប់ហើយនៅស្ងៀម លោកសំណាល់បន្ត ÷

-បើកូនខឹងប៉ា សូប់ប៉ាយ៉ាងណាក៏គួរអាណិតដល់ម៉ាក់កូនដែរ ម៉ាក់កូនទឹកភ្នែករាល់ថ្ងៃឈឺឡើងស្គម ខ្លួនក៏ព្រោះតែនឹកកូន កូនទៅមើលម៉ាក់កូនផង ទុកថាប៉ាអង្វរកូនទៅចុះ។
ឮសំដីឪពុក នាយក្តុកក្តួលចិត្តអាណិតម្តាយចង់ស្រក់ទឹកភ្នែកតែខំទប់ បន្លឺទៅកាន់ឪពុក ៖
-សូមទោសលោកប៉ា អ្វីដែលកូនបានសំរេចចិត្តរួចហើយមិនកែប្រែទេ សូមលោកប៉ាកុំតាមរំខានកូន អី ហើយក៏កុំប្រាប់ម៉ាក់ថាកូនធ្វើការនៅទីនេះដែរ។
-ហ៊ឺស! ប៉ានិយាយអស់ប៉ុណ្ណឹងហើយកូននៅរឹងរូសទៀត។ ល្អ ប៉ានឹងចាំមើលនិងចង់ដឹងថាហ្អែង អាចទ្រាំបានប៉ុន្មានខ្យល់ទៀតទៅ?
លោកក្តៅចិត្តណាស់ខឹងកូនមិនស្តាប់តាមខ្លួន និយាយទៅកាន់មិត្តរួមគុ ៖
-ទៅវិញ បើនៅទៀតអញបាយមិនឆ្ងាញ់ទេ។
បន្លឺចប់ លោកសំណាល់ក្រោកដើរចេញទៅ អ្នករួមតុងទៀតស្រលាំងកាំងបន្តិចនឹងអាកប្បកិរិយា លោកសំណាល់ បន្ទាប់មកក៏ក្រោកចេញទៅដែរ។ អ្នកនៅជុំវិញទាំគ្នាតាមដានហេតុការណ៍នេះ លាយឡំទៅដោយសំនួរនិងចម្លើយដែលមិនច្បាស់លាស់។ ក្រោយពីរឿងនេះបានកើតឡើង ថៅកែភោជនីយដ្ឋានក៏បានបញ្ឈប់នាយពីការងារ ធ្វើឱ្យនាយត្រូវស្វែងរកការងារធ្វើដោយលំបាក ព្រោះកន្លែងមួយចំនួនទោះបីត្រូវការបុគ្គលិក ក៏មិនឱ្យនាយចូលធ្វើការដែរ ដោយសារលោក សំណាល់បានឱ្យកូនចៅដើរហាមប្រាមកន្លែងដែលស្គាល់គ្នា មិនឱ្យទទួលយកនាយឡើយ។ លោក ធ្វើនេះដោយសង្ឃឹមនិងជឿថា នៅពេលកូនអស់ផ្លូវដើរហើយទាល់ច្រកនឹងវិលមកផ្ទះវិញដោយឯក ឯងជាមិនខាន។ ប៉ុន្តែមិនដូចការគិតទុកនេះទេ សុមេធមិនអស់សង្ឃឹមនឹងជីវិតឡើយ នាយនៅ តែតស៊ូព្យាយាមដោយអត់ធ្មត់ស្វែងរកការធ្វើ។

ដោយការសប្បាយភ្លើតភ្លើនភ្លេចខ្លួន មិនយូរប៉ុន្មានលោកសំណាល់ក៏ធ្លាក់ខ្លួនឈឺ។ ពេលទៅ ពិនិត្យអាការរោគនៅមន្ទីរពេទ្យ លទ្ធផលគឺលោកមានជំងឺថ្លើមស្វិត និងតម្រងនោមធ្ងន់ធ្ងរតម្រូវឱ្យ សំរាកនៅមន្ទីរពេទ្យ ដើម្បីធ្វើការព្យាបាល។ ដោយសារតែជំងឺឈានដល់ដំណាក់កាលធ្ងន់រួមផ្សំនឹង ការក្រៀមក្រំចិត្តពីរឿងកូន នាំឱ្យអារម្មណ៍មានទុក្ខព្រួយជាប់ជាប្រចាំ បង្កើតទៅជាជំងឺផ្លូវចិត្តមួយ បណ្តាលឱ្យមេរោគមានឥទ្ធិពលកាន់តែរីករាលដាលយ៉ាងឆាប់រហ័ស ធ្វើឱ្យជំងឺលោកសំណាល់កាន់តែ ធ្ងន់ធ្ងរឡើងៗ រាងកាយស្គាំងស្គមរហូតដេកមួយកន្លែង។ ឃើញស្វាមីធ្លាក់ក្នុងសភាពបែបនេះ លោកស្រីអស់មធ្យោបាយមិនដឹងត្រូវធ្វើយ៉ាងណាគិតតែពីយំ។ ដឹងខ្លួនថាមិនអាចមានជីវិតតទៅ ទៀត លោកសំណាល់បានឱ្យភរិយាតាមរកកូនព្រោះចង់ឃើញមុខជាចុងក្រោយ។ ដើម្បីបំពេញ បំណងស្វាមី លោកស្រីណារីនិងអ្នកបំរើខំតាមរកតែមិនបានផលអ្វីសោះ ក៏ដាច់ចិត្តប្រកាសរកកូន

តាមសារព័ត៌មាន។ នាពេលរសៀលភក្តីបានមកជួបសុមេធ ហុចសារព័ត៌មានទៅឱ្យជាមួយនឹងវាចា បន្តីដោយទឹកមុខស្រងូតស្រងាត់ ៖
-បងអានកាសែតនេះទៅ។
-បងដឹងហើយពីបំណងដែលអូនបងរកបង។
-បើដឹងហើយ ម៉េចក៏បងមិនទៅមើលលោកប៉ាបង?
-បងចង់ទៅដែរ ប៉ុន្តែបងមិនអាច...
-ឬមួយបងគិតថាគាត់ចង់ឱ្យកូនត្រលប់ទៅផ្ទះវិញក៏ធ្វើពុតជាឈឺ តែគាត់ពិតជាឈឺមែនហើយឈឺធ្ងន់ទៀតផង។ ពេលនេះគាត់ចង់ជួបមុខកូនជាចុងក្រោយ ទោះជាគាត់ធ្វើខុសយ៉ាងណាក៏នៅតែជាឪពុកបង ជាអ្នកផ្តល់កំណើតដល់បងដែរ ក្នុងនាមជាកូនកតញ្ញូបងត្រូវតែទៅមើលគាត់។
ពេលបានឮសំដីគូដណ្តឹង ក្នុងចិត្តអាណិតឪពុកដែលជាអ្នកមានគុណ នាយបន្លឺដោយក្រៀមក្រំ៖
-អូននិយាយត្រូវណាស់ ល្អអាក្រក់ខុសត្រូវយ៉ាងណាក៏នៅតែជាឪពុកដែរ កូនត្រូវតែបំពេញតួនាទីជាកូន អរគុណអូនដែលបានជួយរំលឹកបង។
ស្តាប់ហើយភក្តីត្រេកអរណាស់ ក៏បន្លឺឡើង៖
-អញ្ចឹងបងទៅជាមួយអូនពេលនេះទៅ?
ពេលឃើញមុខកូន លោកសំណល់ដេកបង្ហូរទឹកភ្នែកឥតឈប់កាត់ផែនថ្ពាល់ដែលខ្ជងផត ក្នុងចិត្តពោរពេញដោយវិប្បដិសារី ស្តាយក្រោយនូវអំពើដែលបានប្រព្រឹត្តកន្លងមក ដូចពាក្យគេថា «ទាល់តែឃើញក្តារមឈូសបានចេះស្រក់ទឹកភ្នែក» លោកបន្លឺខ្សាវៗមួយៗទៅកាន់កូនប្រុស ៖
-មេធកូន អភ័យទោសឱ្យប៉ាផង ក្នុងលោកនេះមានរឿងច្រើនណាស់ដែលកូនមិនទាន់យល់ គ្មានអ្នកណាម្នាក់ចង់អាក្រក់ទេ តែបរិយាកាសសង្គមតម្រូវឱ្យប៉ាត្រូវតែដើរផ្លូវនេះ ប៉ាគ្រាន់តែចង់ប្រាប់កូនថា «អ្នកដើរកាត់ភ្លៀងរមែងទទឹកភ្លៀង» ថ្ងៃក្រោយកូននឹងយល់សំដីប៉ាមិនខាន។
លោកបែរមកភរិយា ៖
-ណារីអូន បងបានធ្វើខុសធ្ងន់ណាស់ចំពោះអូននិងកូន ព្រោះតែក្តីលោភលន់ សប្បាយភ្លើតភ្លើនភ្លេចខ្លួន ទើបបានជាទទួលលទ្ធផលយ៉ាងនេះ។ នៅពេលដឹងខ្លួនថាខុស គឺហួសពេលទៅហើយ បងស្តាយក្រោយណាស់។
លោកឈប់បន្តិចខំសំរួលដង្ហើម រួចពោលបន្ត ៖
-មេធកូន ប៉ាមិនដែលអង្វរសុំអីពីកូនទេ ពេលនេះ ប៉ាសុំកូនរឿងមួយ តើបានទេ? បានទេកូន?
សុមេធបន្លឺទាំងទឹកភ្នែក ៖

-បាទ លោកប៉ា

-ពេលប៉ាស្លាប់ទៅ សូមកូនត្រលប់មកនៅជាមួយម៉ាក់ជួយមើលថែម៉ាក់កូនជំនួសប៉ាផង ប៉ា..ប៉ា.. លា...លា...ហើយ។

លោកសំណល់ផុតដង្ហើមយ៉ាងអាណោចអាធ័ម លោកស្រីណារីយំសោកបោកខ្លួនមិនគួរស្វាមីស្លាប់មុនអាយុយ៉ាងនេះសោះ សុមេធអាណិតម្តាយនិងសោកស្តាយដោយការបាត់បង់ឪពុក។ ក្រោយពីបានធ្វើបុណ្យសព្វចរាល់ហើយ ម្តាយនិងកូនបានពិភាក្សាគ្នាដោយគិតថា ទ្រព្យសម្បត្តិមួយភាគធំគឺបានមកពីអំពើមិនបរិសុទ្ធត្រូវតែយកទៅជួយជាតិកសាងប្រទេសជួយដល់ប្រជារាស្ត្រ ហើយក៏បានសំរេចលក់ភូមិគ្រឹះ ដីធ្លីនិងរថយន្ត យកប្រាក់មកធ្វើបុណ្យដាក់ទានឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធស្វាមីនិងឪពុក ឱ្យរួចផុតពីទុក្ខទោសនិងបាបកម្មដែលបានសាង ឱ្យបានទៅកាន់ឋានបរមសុខនិងសុគតិភព។ ក្រៅពីនេះលោកស្រីបានយកប្រាក់ទៅសង់សាលារៀន មន្ទីរពេទ្យ ស្ពាន ផ្លូវថ្នល់នៅតាមជនបទ សំរាប់ជាគុណប្រយោជន៍ដល់ប្រជាជនទូទៅ និងឧបត្ថម្ភដល់មជ្ឈមណ្ឌលសង្គ្រោះ មន្ទីរពេទ្យ អង្គការនិងសង្គមស៊ីវិលបំរើផ្នែកមនុស្សធម៌ ជាថវិកា សំភារៈ របស់ហូបចុក ដោយចុះទៅជួបសួរសុខទុក្ខនិងចែកផ្ទាល់ដៃឱ្យដល់ស្ត្រីមេម៉ាយ កុមារកំព្រា ជនពិការ និងអ្នកជំងឺអេដស៍។

មួយឆ្នាំក្រោយមក សុមេធបានបញ្ចប់ការសិក្សា ហើយត្រូវស្វែងរកការធ្វើដោយខ្លួនឯង។ លោកស្រីណារីជាម្តាយក៏បានប្រឹងប្រែងជួយកូន រហូតបានចូលបំរើការក្នុងស្ថាប័នរដ្ឋ មានឋានៈជាមន្ត្រីសាមញ្ញ។ ចូលធ្វើការមិនដល់កន្លះឆ្នាំផង នាយត្រូវបានថ្នាក់លើដំឡើងឋានៈជាអនុប្រធានការិ-យាល័យ ធ្វើឱ្យអ្នករួមការងារទាំងអស់ភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ការឡើងបុណ្យសក្តិនេះ នាយយល់ថាប្រហែលជាថ្នាក់លើបានមើលឃើញការខិតខំនិងសមត្ថភាពការងាររបស់ខ្លួន។ ពីរខែបន្ទាប់មក ថ្នាក់លើក៏បានដំឡើងឋានៈនាយបន្ថែមជាប្រធានការិយាល័យ។ ម្តងនេះ នាយចាប់ផ្តើមឆ្ងល់ ហេតុអ្វីក៏ខ្លួនឡើងបុណ្យលឿនម្ល៉េះ? តែរកហេតុផលមិនឃើញសោះ។

ថ្ងៃមួយ សុមេធបានទទួលសំណុំឯកសារមួយពីភ្ញៀវ មានទាំងស្រោមសំបុត្រមួយផង។ នាយបើកមើលឃើញក្នុងនោះមានប្រាក់១ ០០០ដុល្លារ។ នាយចង់សើចបន្តិចចង់ខឹងបន្តិច ពិនិត្យឯកសាររួចប្រគល់ឱ្យភ្ញៀវវិញ។ ភ្ញៀវខំនិយាយអង្វរយ៉ាងណាក៏នាយមិនទទួល ដោយមូលហេតុឯកសារមិនត្រឹមត្រូវនិងមិនស្របច្បាប់។ ឃើញភាពម៉ឺងម៉ាត់របស់សុមេធ ភ្ញៀវអស់ពាក្យនិយាយ ក៏ទទួលឯកសាររួចចេញទៅទាំងចិត្តមួហ្មង។

នាពេលល្ងាចក្រោយម៉ោងការងារ លោកនាយកធំបានហៅសុមេធចូលជួប។ នៅចំពោះមុខកូនចៅ លោកបន្លឺដោយគ្មានលាក់លៀម ៖

-ព្រឹកមិញភ្ញៀវយកឯកសារមកឱ្យស៊ីញ៉េ ហេតុអីក៏មេធងងមិនស៊ីញ៉េ?
-បាទលោកនាយក ឯកសារនោះមិនត្រឹមត្រូវនិងខុសច្បាប់ ខ្ញុំមិនអាចស៊ីញ៉េបានទេ។
-ឯងគ្រាន់តែស៊ីញ៉េរួចបញ្ជូនមកឱ្យខ្ញុំជាអ្នកសំរេចតើ មានទៅទាស់ខុសអី? គ្រាន់តែមួយខ្វាច់បាន ១ ០០០ដុល្លារ ឯងទៅរកឯណាបាន ឬមួយគិតថាតិចពេក?
លោកក្រោកដើរមកទះស្មាកូនចៅតិចៗព្រមជាមួយពាក្យដាស់តឿន ៖
-កុំល្ងង់ពេក បើឯងមិនស៊ីក៏មានគេស៊ីដែរ ធ្វើជាមនុស្សត្រូវចេះ «ចូលស្ទឹងតាមបទ» ទើបអាចរស់បានដោយសុខស្រួលនិងគ្មានគ្រោះភ័យផង។
សុមេធហួសចិត្តនឹងសំដីនេះ តបវិញយ៉ាងក្លាហាន ៖
-ព្រោះតែគ្រប់គ្នាគិតអញ្ចឹងហើយបានជាប្រទេសជាតិមិនរីកចំរើនទៅមុខសោះ។ ប្រជាជននៅតែក្រ ម្នាក់ៗគិតតែពីប្រយោជន៍ផ្ទាល់ខ្លួននិងបក្សពួកនាំគ្នាប្រព្រឹត្តអំពើពុករលួយ លួចទ្រព្យសម្បត្តិជាតិយកមកធ្វើមានបាន រស់សោយសុខលើគំនរទុក្ខរាស្ត្រ។
សំដីសុមេធធ្វើឱ្យលោកនាយកថ្លោះទឹកមុខ បន្លឺគំរាម ៖
-បើឯងប្រឆាំងនឹងខ្ញុំដឹងថាលទ្ធផលទៅជាយ៉ាងណាទេ? ក្នុងរយៈពេលតែ២៤ម៉ោង ឯងនឹងត្រូវខ្ចាតពីតំណែង ឯងជឿទេ?
-ខ្ញុំជឿ លោកជាមេ មានសិទ្ធិមានអំណាចចង់ធ្វើអីក៏បានដែរ។
-អញ្ចឹងឯងជួយសំរួលរឿងនោះផង ចាំខ្ញុំឱ្យឯងថែមទៀត។
-សុំទោស ខ្ញុំមិនអាចធ្វើតាមបញ្ជាលោកដោយក្បត់ឧត្តមគតិនិងមនសិការខ្លួនឯងទេ។
មិនសមតាមបំណង លោកនាយកខឹងណាស់ ៖
-ហ៊ឺស! ស្រាផ្អែមឯងមិនចង់ផឹកបែរជាចង់ផឹកស្រាល្វីង អស់កិច្ចការហើយឯងចេញទៅវិញចុះ។
ស្អែកឡើងសុមេធទៅធ្វើការដូចសព្វដង ស្រាប់តែមានសេចក្តីសំរេចពីថ្នាក់លើដកតំណែងនិងបញ្ឈប់នាយពីការងារដោយមិនមានមូលហេតុច្បាស់លាស់ ធ្វើឱ្យអ្នករួមការងារទាំងអស់ភ្ញាក់ផ្អើលម្តងទៀត ព្រោះដូចជាឡើងចុះរហ័សពេក។ បានទទួលដំណឹងនេះហើយ នាយក៏រៀបចំការងារប្រគល់ឱ្យអ្នកថ្មីដោយមិនមានការតវ៉ា តូចចិត្ត ឬសោកស្តាយអ្វីឡើយ មានតែសប្បាយចិត្តទៅវិញទេដែលខ្លួនបានរួចផុតពីការទទឹកភ្លៀងព្រោះមិនមែនជាអ្នកដើរកាត់ភ្លៀងទៀតទេ។
ពីរ បីថ្ងៃមកហើយមិនឃើញកូនទៅធ្វើការ លោកស្រីណារីសួរកូនប្រុសដោយងឿងឆ្ងល់ ៖
-ប៉ុន្មានថ្ងៃនេះម៉ាក់មិនឃើញកូនទៅធ្វើការ តើមានរឿងអី?
-គេបញ្ឈប់ការងារខ្ញុំហើយម៉ាក់។

-ពុទ្ធោ! នេះកូននិយាយមែនឬលេង? ម៉ាក់ខំទាក់ទងទំរាំបានការឱ្យកូនធ្វើ អស់លុយអស់កាក់ អើ... លោកស្រីដឹងថាខ្លួនជ្រុលមាត់ ក៏ឈប់និយាយ។ តែសុមេធចាប់សំដីម្ដាយបាន សួរភ្លាមទាំងហួសចិត្ត ÷

-ម៉ាក់និយាយថាម៉េច? ម៉ាក់យកលុយទៅទិញកន្លែងឱ្យកូនមែនទេ?

-ម៉ាក់គ្រាន់តែចង់ឱ្យកូនមានអនាគតល្អ មិន...

-អញ្ចឹងតើ បានជាបុណ្យស័ក្ដិកូនឡើងតាមជើងខោ។ ម៉ាក់មានគិតទេ កូនអ្នកក្រដែលកំពុងអត់ការធ្វើ ហើយគ្មានលុយសូកគេនោះ តើពួកគេឈឺចាប់និងតូចចិត្តយ៉ាងណា? កូនចង់ធ្វើអ្វីៗគឺពឹងលើចំណេះនិងសមត្ថភាពខ្លួន មិនមែនដោយអំពើមិនស្អាតស្អំនោះទេ។ ម៉ាក់មិនគួរធ្វើយ៉ាងនេះសោះ។

-ឱ្យម៉ាក់សុំទោស ព្រោះតែម៉ាក់គិតថាធ្វើការរដ្ឋអាចជួយប្រទេសជាតិនិងមានកិត្តិយស។

-ម៉ាក់គិតនេះខុសហើយ មិនមែនទាល់តែចូលបំរើការរដ្ឋទើបជាអ្នកស្រលាញ់ជាតិជួយប្រជារាស្ត្រនិងមានតម្លៃមានមុខមាត់នោះទេ ធ្វើការជាមួយអង្គការ ឬសង្គមស៊ីវិលក៏ជួយជាតិបំរើរាស្ត្រដូចគ្នា សំខាន់គឺត្រូវមានឧត្តមគតិនិងមនសិការជាតិ។

-តែការងារឥឡូវពិបាករកណាស់ណា ម៉ាក់បារម្ភ...

-ម៉ាក់ទុកចិត្តចុះ កូននឹងស្វែងរកការធ្វើតាមលទ្ធភាពខ្លួនឱ្យទាល់តែបាន កូនមិនជឿថាទេវតាមិនជួយមនុស្សល្អទេ។

ចាប់ពីពេលនោះមក សុមេធបានដើររកការងារធ្វើនៅតាមកន្លែងជាច្រើនតែមិនបានលទ្ធផលអ្វីសោះ តែនាយមិនអស់សង្ឃឹមទេ នៅតែខំប្រឹងប្រែងរកតទៅទៀត។ ថ្ងៃមួយ សុមេធបានជួបនឹងជនបរទេសម្នាក់ដោយចៃដន្យ ហើយបានសន្ទនាគ្នាយ៉ាងស្និទ្ធស្នាល។ ដោយឃើញថានាយយើងនិយាយភាសាអង់គ្លេសបានល្អនិងដឹងថាកំពុងស្វែងរកការធ្វើ ជនបរទេសនោះក៏បានណែនាំឱ្យចូលធ្វើការនៅអង្គការក្រៅរដ្ឋាភិបាលមួយដែលទើបនឹងបង្កើតក្នុងឋានៈជាបុគ្គលិក។ សុមេធបានខិតខំយកចិត្តទុកដាក់បំពេញការងារដោយស្មារតីខ្ពស់ ម៉ឺងម៉ាត់ម៉ត់ចត់ បានទទួលការស្រលាញ់ពេញចិត្តនិងការសរសើរពីក្រុមប្រឹក្សានាយកអង្គការ។ ក្រោយពីបានតាមដានប្រវត្តិការងារដឹងថាជាយុវជនមានគុណធម៌ មិនយូរប៉ុន្មានក្រុមប្រឹក្សានាយកក៏បានសំរេចដំឡើងឋានៈសុមេធជាប្រធានគ្រប់គ្រង។ នៅក្នុងតំណែងថ្មីដែលបានដោយសារចំណេះនិងសមត្ថភាពពិតប្រាកដរបស់ខ្លួន សុមេធបានបង្កើតកម្មវិធីថ្មីៗមួយចំនួនទៀតជួយដល់ជនក្រីក្រ កុមារកំព្រាអនាថា ចាស់ជរា ពិការ ។ល។ បន្ទាប់ពីបានការធ្វើមានស្ថេរភាពល្អហើយ ឪពុកម្ដាយទាំងសងខាងក៏បានរៀបចំមង្គលការកូនសុមេធនិងភក្តីជាគូស្វាមីភរិយា ហើយបានរួមរស់ជាមួយគ្នាយ៉ាងសុខសាន្ត។

«ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់» ជាពាក្យដែលគេតែងនិយាយនៅពេលកូនកាត់ទៅរកឪពុក ប៉ុន្តែនៅពេលស្លឹកឈើជ្រុះហើយមានខ្យល់បក់ផាត់នោះ ស្លឹកឈើក៏អាចហើរតាមកំលាំងខ្យល់ទៅជ្រុះឆ្ងាយពីដើមបានដែរ។ សុមេធជាបញ្ញវ័ន្តមានការអប់រំល្អ មានគុណធម៌ មានសម្បជញ្ញៈប្រកបទៅដោយឧត្តមគតិនិងមនសិការ គឺជា «ស្លឹកឈើជ្រុះឆ្ងាយពីគល់»៕